សំរាប់ព័ត៌មានបន្ថែមទៀតពីកម្មវិធីត្រួតពិនិត្យទារកក្នុងរដ្ឋរបស់លោក-អ្នក រួមបញ្ចូលទាំង ការពិនិត្យឲ្យបានជាក់លាក់លើលក្ខណៈណាមួយ សូមមេត្តាទាក់ទង:

## Connecticut (រដ្ឋខន្និតិខាត់)

State of Connecticut, Public Health Laboratory
10 Clinton Street, P.O. Box 1689
Hartford, CT 06144
(860) 509-8081
www.ct.gov/dph

## Maine (រដ្ឋម៉េន)

Newborn Screening Program, Dept. of Health & Human Services
Key Bank Plaza - 7th Floor, 286 Water Street
Augusta, ME 04333
(207) 287-5357
www.maine.gov/dhhs/boh/cshn/bloodspot_screening/index.html

## Massachusetts (រដ្ឋម៉ាស្សាជូសេត្ស៍)

New England Newborn Screening Program
University of Massachusetts Medical School
305 South Street
Jamaica Plain, MA 02130-3515
(617) 983-6300
www.umassmed.edu/nbs

## New Hampshire (រដ្ឋញ៉ូហេមស្ស៊ឺ)

Maternal & Child Health Section
29 Hazen Drive
Concord, NH 03301-6504
(603) 271-4225
www.dhhs.state.nh.us/dhhs/mch.htm

## Rhode Island (រដ្ឋរ៉ូតអៃស៍ឡៀន)

Rhode Island Department of Health
3 Capitol Hill, Room 302
Providence, RI 02908-5097
(800) 942-7434
www.health.ri.gov/genetics/newborn.php

## Vermont (រដ្ឋវឺម៉ុនត៍)

Vermont Department of Health, Children with Special Health Needs
108 Cherry Street, P.O. Box 70
Burlington, VT 05402
(802) 951-5180

**Khmer (Cambodian)**

# ការត្រួតពិនិត្យទារក:
# ការពិនិត្យនោះអាចសង្គ្រោះជីវិតទារករបស់លោក -អ្នក



Sponsored in part by a grant from the Genetic Services Branch of the Maternal and Child Health Bureau (MCHB) of the Health Resources and Services Administration (HRSA) and the New England Regional Genetics and Newborn Screening Collaborative, HRSA Grant #1U22MC03959. 2008

### ហេតុអ្វីបានជាកូនរបស់ខ្ញុំត្រូវការពិនិត្យរោគពេលទើបតែកើត?

តាមច្បាប់ គេត្រូវតែត្រួតពិនិត្យទារកទើបតែកើតទាំងអស់រកមើលជំងឺដែលកម្រពីរ-បីប្រភេទ ប៉ុន្តែកាចសាហាវ។ ទារកដែលមានជំងឺនេះមើលទៅហាក់ដូចជាមានសុខភាពល្អពេលទើបតែកើត។ បើសិនជាមិនពិនិត្យ អាការៈរោគទាំងនោះអាចប៉ះទង្គិចដល់សុខភាព ដូចជាភាពពិការខួរក្បាល ការលូតលាស់យឺតយាវ ឬក៏រហូតដល់បាត់បង់ជីវិតតែម្តង។ បើមានការព្យាបាល បញ្ហាទាំងនោះអាចការពារទៅបាន។

### តើគេត្រូវពិនិត្យរោគកូនរបស់ខ្ញុំដោយវិធីណា?

គ្រូពេទ្យ ឬក៏អ្នកជំនាញផ្នែកវេជ្ជសាស្រ្តដទៃទៀតនឹងជួសយកឈាមពីរ-បីដំណក់ពីកែងជើងទារករបស់លោក-អ្នក។ ឈាមដែលគេជួសនោះនឹងត្រូវគេបញ្ជូនទៅមន្ទីរពិសោធន៍ពិនិត្យទារកដែលទើបតែកើត។

### តើនៅពេលណាទើបឈាមនោះគួរតែត្រូវគេជួស?

ឈាមគួរតែត្រូវគេជួសបន្ទាប់ពីទារកនោះមានអាយុ ២៤ម៉ោង ប៉ុន្តែមុនពេលដែលទាររបស់លោក-អ្នកចាកចេញពីមន្ទីរពេទ្យ។

### តើខ្ញុំអាចទទួលលទ្ធផលនៃការពិនិត្យឈាមនោះដោយវិធីណា?

វេជ្ជបណ្ឌិតទារករបស់លោក-អ្នកនឹងទាក់ទងលោក-អ្នក បើសិនជាលទ្ធផលនោះបង្ហាញថា កូនរបស់លោក-អ្នកអាចមានលក្ខណៈរោគណាមួយ។ វេជ្ជបណ្ឌិតនឹងពិភាក្សាជាមួយលោក-អ្នកពីលទ្ធផល ហើយនិងអ្វីដែលត្រូវធ្វើជាបន្ទាប់ទៅទៀត។
ចូរសួរពីលទ្ធផលនៃការពិនិត្យរោគនៅពេលដែលលោក-អ្នកជួបពេទ្យរបស់កូនលោក-អ្នក។

### តើត្រូវធ្វើយ៉ាងដូចម្តេច បើសិនជាកូនខ្ញុំត្រូវគេពិនិត្យម្តងទៀត?

ជួនកាល ទារកត្រូវគេពិនិត្យមើលសារជាថ្មី។ នេះមិនមែនមានសេចក្តីថា កូនរបស់លោក-អ្នកមានជម្ងឺឡើយ។ គេគ្រាន់តែត្រូវពិនិត្យម្តងទៀតតែប៉ុណ្ណោះ បើសិនៈ

- ការជួសឈាមត្រូវគេធ្វើមុនពេលទារកមានអាយុ ២៤ម៉ោង
- មានបញ្ហាពាក់ព័ន្ធនឹងវិធីការជួសឈាម
- ការជួសឈាមលើកដំបូងបង្ហាញពីរោគសញ្ញានៃជម្ងឺណាមួយ

វេជ្ជបណ្ឌិតរបស់ទារកលោក-អ្នក ឬក៏កម្មវិធីពិនិត្យទារកទើបតែកើតក្នុងរដ្ឋលោក-អ្នកនឹងទាក់ទងលោក-អ្នក បើសិនជាទារករបស់លោក-អ្នកត្រូវការពិនិត្យថែមទៀត។ វាជាការសំខាន់ណាស់ក្នុងការ ឲ្យគេពិនិត្យជាបន្ទាន់។



### តើការពិនិត្យអ្វីខ្លះគេត្រូវតែធ្វើ?

ការពិនិត្យផ្សេងៗអាស្រ័យតាមរដ្ឋដែលលោក-អ្នករស់នៅ។ រដ្ឋនិមួយៗ ធ្វើការពិនិត្យខុសគ្នាបន្តិចបន្តួចតាមលក្ខណៈនៃជម្ងឺ។ ជាទូទៅ រោគដែលគេពិនិត្យមើលនោះនៅក្នុងចំណោមរោគរាយឈ្មោះខាងក្រោមនេះ:



- លក្ខណៈនៃការចំរាញ់ ដែលទាក់ទងទៅនឹង ដំណើរការដែលរាងកាយរំលាយអាហារ
- លក្ខណៈនៃអ៊ីនដុកគ្រីន ដែលទាក់ទងទៅនឹងកំរិតអ័រម៉ូនសំខាន់ៗ
- លក្ខណៈឈាមស ដែលអាចទាក់ទងទៅនឹងឈាមក្រហម ហើយអាចបណ្តាល ឲ្យខ្វះឈាម មានការក្លាយ ហើយនិងបញ្ហាសុខភាពដទៃទៀត
- លក្ខណៈស្លួត ដែលអាចទាក់ទងទៅនឹងការលូតលាស់ហើយនិងស្លួត

សំរាប់ឈ្មោះនៃលក្ខណៈផ្សេងៗដែលគេពិនិត្យនៅក្នុងរដ្ឋរបស់លោក-អ្នក សូមទាក់ទងទៅកម្មវិធីពិនិត្យជម្ងឺទារកទើបតែកើត ឬក៏សួរវេជ្ជបណ្ឌិតរបស់ទារកលោក-អ្នក។

ការពិនិត្យរោគដទៃទៀតអាចមាននៅតាមមន្ទីរពិសោធន៍នានាដោយមានការបង់ប្រាក់។

### តើអាការៈទាំងនេះត្រូវគេព្យាបាលដោយវិធីណា?

ការព្យាបាលចំពោះរោគនិមួយៗ មានភាពខុសគ្នា។ ការព្យាបាលអាចរួមបញ្ចូលទាំងការទទួលទានចំណីអាហារពិសេស អ័រម៉ូន ហើយនិងការលេបថ្នាំ។

បើសិនជាទារករបស់លោក-អ្នកមានរោគណាមួយក្នុងចំណោមជម្ងឺទាំងនេះ វាជាការចាំបាច់ណាស់ក្នុងការចាប់ផ្តើមការព្យាបាលជាបន្ទាន់ដែលអាចធ្វើទៅបាន។

### តើត្រូវធ្វើយ៉ាងម៉េចបើសិនជាខ្ញុំមានសំណួរដទៃទៀត?

សួរវេជ្ជបណ្ឌិតរបស់ទារកលោក-អ្នក ឬក៏ទាក់ទងទៅកម្មវិធីពិនិត្យទារកទើបតែកើត។ សូមមេត្តាមើលខាងខ្នងនៃសន្លឹកនេះដើម្បីរកកន្លែងនៃកម្មវិធីពិនិត្យទារកទើបតែកើតនៅក្នុងតំបន់ញូអ៊ីងគ្លេន។